**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩*

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាង «យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»

នាព្រឹកថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩, នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.), គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គ.ស.ហ.) បានប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាង «**យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥**» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន គ.ស.ហ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមទេសរដ្ឋមន្ត្រី, ឯកឧត្តមរដ្ឋមន្ត្រី, រដ្ឋលេខាធិការប្រចាំការ ជាសមាជិកនៃ គ.ស.ហ., លោកជំទាវទេសាភិបាលរង នៃធនាគារជាតិនៃកម្ពុជា, ថ្នាក់ដឹកនាំសហគ្រាសសាធារណៈ, រដ្ឋបាលថ្នាក់ក្រោមជាតិ, ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃ ក.ស.ហ.វ.។

សេចក្ដីព្រាង «**យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥**» ត្រូវបានដាក់ឆ្លងកិច្ចពិគ្រោះយោបល់ជាបន្តបន្ទាប់ ជាមួយតួអង្គពាក់ព័ន្ធនានា ដូចជា÷ ក្រសួងស្ថាប័ន, ដៃគូអភិវឌ្ឍន៍, សហគ្រាសសាធារណៈ, គ្រឹះស្ថានរដ្ឋបាលសាធារណៈ, និងអគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្រោមឱវាទ ក.ស.ហ.វ. ដែលកិច្ចពិគ្រោះយោបល់ចុងក្រោយបំផុត ត្រូវបានធ្វើឡើងក្នុងកម្រិតថ្នាក់ដឹកនាំ ក.ស.ហ.វ. ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ដើម្បីធានាបាននូវភាពគ្រប់ជ្រុងជ្រោយ មុននឹងយកមកដាក់ឆ្លងកិច្ចប្រជុំ គ.ស.ហ. នាពេលនេះ។

សេចក្តីព្រាងយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសនៃ ក.ស.ហ.វ. ដោយមានការសិក្សា និងវិភាគលើទិដ្ឋភាពរួមនៃការវិនិយោគសាធារណៈ ដែលរួមមាន÷ បរិការណ៍ និងនិន្នាការសកល, ព្រមទាំងបរិការណ៍, បញ្ហាប្រឈម, និងកាលានុវត្តភាពរបស់កម្ពុជា ហើយនឹងដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ និងរយៈពេលមធ្យមមួយចំនួន សំដៅបង្កើតប្រព័ន្ធរួមមួយរបស់ជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន គ្រប់កម្រិតរដ្ឋបាល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, សហគ្រាសសាធារណៈ, និងអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នាជាជំហានៗ ដែលរួមមាន÷ ១)-ការចាប់ផ្តើមពីការពិនិត្យ និងកែសម្រួលនូវក្របខ័ណ្ឌគតិយុត្ត, ២)-ការកំណត់សមត្ថកិច្ចស្ថាប័ន និងការពង្រឹងយន្តការស្ថាប័ននៅតាមដំណាក់កាលនីមួយៗនៃវដ្តគម្រោង, ៣)-ការរៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុ, និង ៤)-ការរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

ការឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ នឹងធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមួយចំនួន, ផ្លាស់ប្តូររបៀបរបបបំពេញការងារ, ព្រមទាំងត្រូវការបំពេញលក្ខខណ្ឌជាច្រើនថែមទៀត ដើម្បីឱ្យសំណើគម្រោងវិនិយោគសាធារណៈមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលចាំបាច់ទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធ ជាពិសេស ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវតែបុរេសកម្ម, សកម្ម, អន្តរសកម្ម និងម៉ឺងម៉ាត់ជាងមុន ដើម្បី មិនត្រឹមតែធានាថាគ្មានការរាំងស្ទះដល់ចលនាការអភិវឌ្ឍប្រទេស ដោយសារការជាប់គាំងនៃគម្រោងវិនិយោគសាធារណៈនៅដំណាក់កាលណាមួយនោះទេ, តែថែមទាំងជួយលើកកម្ពស់ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការវិនិយោគសាធារណៈឱ្យកាន់តែប្រសើរជាងមុនទៀតផង។ ក្នុងស្មារតីនេះ, អភិក្រមនៃការអនុវត្ត ត្រូវតែធ្វើដោយ ***ប្រយ័ត្នប្រយែង, សន្សឹមៗ, ឈរលើគោលការណ៍ប្រាកដនិយម, ទន់ភ្លន់, និង«រៀនផង-ធ្វើផង»***។

អង្គប្រជុំបានវាយតម្លៃខ្ពស់អំពីសារៈសំខាន់នៃ **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»** នេះ ហើយបានពិភាក្សាស៊ីជម្រៅលើខ្លឹមសារតាមផ្នែកនីមួយៗនៃសេចក្តីព្រាង សំដៅធានាបាននូវសង្គតិភាព និងភាពប្រឡាក់ក្រឡា ជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមតិយោបល់ល្អៗ របស់សមាជិក-សមាជិកា នៃអង្គប្រជុំ ព្រមទាំងបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារបច្ចេកទេសនៃ ក.ស.ហ.វ. ដែលបានរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ៕